# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីអំពី <<លទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសម្រាប់កិច្ចសហប្រតិបត្តិការ នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក (ទីក្រុង ប៉ារីស ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២)>>

**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ (១៣:០០នាទី-១៨:០០នាទី)**

**សណ្ឋាគារ Raffle Le Royal Hotel (ទម្រង់ចូលរួមផ្ទាល់ និងតាមប្រព័ន្ធវីដេអូ) រាជធានីភ្នំពេញ កម្ពុជា**

វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) រួមសហការជាមួយប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា និងស្ថានទូតបារាំងនៅកម្ពុជា នឹងសហការរៀបចំវគ្គសិក្ខាសាលាលើកទី២ស្តីអំពី "លទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក (ទីក្រុងប៉ារីស ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២)" នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ (ចាប់ពីម៉ោង ១៣:០០នាទី-១៨:០០នាទី) នៅសណ្ឋាគារ Raffle Le Royal Hotel ជាទម្រង់ចូលរួមផ្ទាល់ និងតាមប្រព័ន្ធវីដេអូដែលនឹងមានការផ្សាយផ្ទាល់តាមគេហទំព័រហ្វេសប៊ុក និងយូធូបរបស់ AVI។

សិក្ខាសាលានេះនឹងផ្តោតសំខាន់ទៅលើកិច្ចពិភាក្សាលើប្រធានបទចំនួនពីររួមមាន៖ (១)សន្តិសុខ និងការការពារ និង(២)ការផ្សារភ្ជាប់ និងឌីជីថល ដែលបានធ្វើឡើងនៅក្នុងវេទិកាប្រជុំថ្នាក់រដ្ឋមន្ត្រីសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលសហការរៀបចំដោយក្រុមប្រឹក្សាសហភាពអឺរ៉ុបដែលមានប្រទេសបារាំងជាប្រធាន តំណាងជាន់ខ្ពស់គោលនយោបាយសន្តិសុខនិងកិច្ចការបរទេស និងអនុប្រធានគណៈកម្មការអឺរ៉ុប ចូស៊ីប ប៉ូរ៉េល ហ្វុងតេលេស (Josep Borrell Fontelles) កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ នៅទីក្រុងប៉ារីស ប្រទេសបារាំង។

អ្នកចូលរួមសិក្ខាសាលានេះរួមមានក្រសួងរដ្ឋាភិបាលកម្ពុជា ស្ថានទូតបរទេសនៅទីក្រុងភ្នំពេញ អង្គការក្រៅរដ្ឋាភិបាលក្នុងនិងក្រៅប្រទេស ស្ថាប័នសិក្សាស្រាវជ្រាវ គ្រឹះស្ថានសិក្សា អ្នកសង្កេតការណ៍នៅកម្ពុជា ក្រុមបញ្ញវ័ន្ត អ្នកជំនាញ និងសិស្សានុសិស្សនៅក្នុងប្រទេសនិងតំបន់។

ព្រឹត្តិការណ៍នេះរៀបចំឡើងដើម្បីប្រមូលធាតុចូលអំពីការប្តេជ្ញាចិត្តរបស់សហភាពអឺរ៉ុបនៅក្នុងតំបន់ក្រោមយុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបអំពីកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលបានចូលជាធរមាននៅខែកញ្ញា ឆ្នាំ២០២១។ ព្រឹត្តិការនេះផ្តល់នូវសកម្មភាពជាក់ស្តែងដែលកើតចេញពីយុទ្ធសាស្ត្រដែលបូកបញ្ចូលគ្នារវាងការផ្តល់យោបល់កម្រិតគោលនយោបាយប្រកបដោយភាពប្រាកដ

ប្រជានៅក្នុងកិច្ចសហប្រតិបត្តិការសន្តិសុខ និងការការពារ ក៏ដូចជាការផ្សារភ្ជាប់ និងឌីជីថលសម្រាប់បណ្តារដ្ឋនៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ទាំងមូល។

វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) គឺជាស្ថាប័នស្រាវជ្រាវឯករាជ្យមួយនៅកម្ពុជាដែលកំពុងខិតខំផ្តល់នូវទស្សនវិស័យជាមួយគោលគំនិតប្រកបដោយការច្នៃប្រឌិតទៅលើបញ្ហាដែលកំពុងកើតមាននៅសង្គមអាស៊ាន។ AVI មានគោលបំណងធ្វើការសិក្សាស្រាវជ្រាវទៅលើកម្មវិធីស្រាវជ្រាវ និងគោលនយោបាយជាក់ស្តែង បង្កើនការចែករំលែកចំណេះដឹង កសាងភាពជាអ្នកដឹកនាំ និងកសាងសមត្ថភាពប្រកបដោយការច្នៃប្រឌិត។ បច្ចុប្បន្ននេះវិទ្យាស្ថានមាន ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា ជាប្រធានក្រុមប្រឹក្សាភិបាល និង លោកបណ្ឌិត ឈាង វណ្ណារិទ្ធិ ជាប្រធានវិទ្យាស្ថាន។

**ព័ត៌មានទំនាក់ទំនង**
**លោកស្រី លឹម ស្រីណិត ប្រធានផ្នែកទំនាក់ទំនងសាធារណៈ និងកសាងដៃគូ**
**អ៊ីម៉ែល៖** asianvisioninstitute@gmail.com
**វេបសាយ៖** www.asianvision.org